**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១៥៥៤ សហវ.អលក

ថ្ងៃច័ន្ទ ១៥កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩

**ជម្រាបជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**កម្មវត្ថុ** : ករណីសំណើសុំអនុម័តការចរចាថ្លៃ និងប្រគល់កិច្ចសន្យាស្ដីពីការងារស្ថាបនាផ្លូវដោយក្រាលក្រួសក្រហម ប្រវែង ២ ៤០០ម ទទឹង ៨ម ស្ថាបនាលូបេតុងមុខកាត់ ១ម ១ជួរ ចំនួន ០៣កន្លែង បំពាក់ស្លាកសញ្ញាចរាចរណ៍ ចំនួន ០៨ដើម ដាំបង្គោលនាំផ្លូវ ចំនួន ១២បង្គោល និងដាក់ស្លាកព័ត៌មានគម្រោង ចំនួន ០២ស្លាក លើកំណាត់ផ្លូវខេត្តបំបែកពីផ្លូវជាតិលេខ៥ ត្រង់គ.ម១៦១+០៥០ ស្ថិតនៅក្នុងឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់។

**យោង** :
- លិខិតលេខ៩០៦៣ សហវ.អថ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កំណត់ហេតុចរចាថ្លៃថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ គ.ល ក្រសួងសាធារណការ និងដឹកជញ្ជូន
- លិខិតលេខ១៧២ សក.អល ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្ដមទេសរដ្ឋមន្ត្រីជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ប្រគល់កិច្ចសន្យាជូននាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ ដើម្បីធ្វើការងារស្ថាបនាផ្លូវដោយក្រាលក្រួសក្រហម ប្រវែង ២ ៤០០ម ទទឹង ៨ម ស្ថាបនាលូបេតុងមុខកាត់ ១ម ១ជួរ ចំនួន ០៣កន្លែង បំពាក់ស្លាកសញ្ញាចរាចរណ៍ ចំនួន ០៨ដើម ដាំបង្គោលនាំផ្លូវ ចំនួន ១២បង្គោល និងដាក់ស្លាកព័ត៌មានគម្រោង ចំនួន ០២ស្លាក លើកំណាត់ផ្លូវខេត្តបំបែកពីផ្លូវជាតិលេខ៥ ត្រង់គ.ម១៦១+០៥០ ស្ថិតនៅក្នុងឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់ ក្នុងតម្លៃសរុបចំនួន ៩១៦.០០០.០០០រៀល (ប្រាំបួនរយដប់ប្រាំមួយលានរៀលគត់) ជាតម្លៃកិច្ចសន្យា។

ការជួលបន្តទៅឱ្យក្រុមហ៊ុនឯកជនត្រូវបានហាមឃាត់ដាច់ខាត។ បើអង្គភាពរដ្ឋណាមួយគ្មានលទ្ធភាពធ្វើខ្លួនឯងបាន ត្រូវដកហូតប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តវិញ។ ក្នុងករណីប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្ត ត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្ដមទេសរដ្ឋមន្ត្រីជ្រាប និងមានវិធានការអនុវត្តបន្តឱ្យសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ។

សូមឯកឧត្ដមទេសរដ្ឋមន្ត្រី ទទួលនូវគារវកិច្ចពីខ្ញុំ។

**ស. ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រដ្ឋលេខាធិការ**

**ជូ-វីជិត្ត**

ចម្លងជូន
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានថវិកា
- សាលាខេត្តពោធិ៍សាត់
- នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ
- នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈ
- មន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តពោធិ៍សាត់
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តពោធិ៍សាត់
- ឯកសារ- កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798